# កុមារភាព បងប្អូន និង កិច្ចការរបស់ឪពុកខ្ញុំ

ខ្ញុំដឹងក្តីឡើងក្រោមការចិញ្ចឹមបីបាច់ថែរក្សារបស់ឪពុកម្តាយខ្ញុំ ។ ខ្ញុំមានបង ២ នាក់ទៀត បងបង្អស់ឈ្មោះ ឈឿន ហៅក្រៅថាបង "នាង" និង បងបន្ទាប់ឈ្មោះ ស៊ីនឿន ហៅបង "ផាត" ។ នៅក្នុងផ្ទះរបស់យើងៗនៅជាមួយជីដូនខ្ញុំគឺ លោកយាយ អ៊ុង គូ និង ម្តាយមីងខ្ញុំគឺ អ្នកមីងសាម៉ុឌី ។ ខ្ញុំមិនបានស្គាល់លោកយាយ ហ៊ូឱ ខាងឪពុកខ្ញុំទេ ដោយហេតុថាលោកយាយបានស្លាប់ជាយូរឆ្នាំទៅហើយ ។ ឪពុកម្តាយខ្ញុំមិនមានអ្នកបរទេះ ឬ អ្នកបម្រើធ្វេងស្តាំដូចជីតាខ្ញុំទេ ។ ម្តាយខ្ញុំជាប់រវល់ការងារមេផ្ទះ ធ្វើម្ហូបអាហារ និង ថែទាំកូនចៅ ដោយមានជំនួយការពីបងជីដូនមួយខ្ញុំខ្លះ ដែលត្រូវជាក្មួយរបស់ឪពុកខ្ញុំ ។ កាលខ្ញុំនៅតូចៗនៅឡើយ បងស្រីដែល

នៅជួយមើលថែទាំខ្ញុំឈ្មោះ បងជ្រូក ។ បងជ្រូក មកស្នាក់នៅជាមួយពួកយើង ដើម្បីរៀនបញ្ចប់ថ្នាក់បឋមសិក្សា យកសញ្ញាប័ត្រទៅប្រឡងចូលធ្វើមន្ត្រីរាជការ ។ នៅពេលចេញពីសាលា បងជ្រូកតែងជួយធ្វើការម្ដាយខ្ញុំ មើលថែទាំខ្ញុំ នាំខ្ញុំដើរលេងផង និង ច្រៀងបំពេរលួងកុំឲ្យខ្ញុំយំផង ។ ដោយសារខ្ញុំនៅតូចពេក កាលពេលនោះ ខ្ញុំពុំមានចាំទុកនូវអនុស្សាវរីយ៍ណាមួយជាមួយបងជ្រូកទេ ។ ក្រោយមកបងជ្រូក បានប្រឡងជាប់ជាធ្មបរដ្ឋ ។ ខ្ញុំឮថានៅសម័យសង្គមបងជ្រូក បានប្ដីជាសហគ្រិន ហើយមានជីវភាពធូរធារ រហូតមានផ្ទះថ្មមួយល្វែងធំ ស្ថិតនៅតាមមហាវិថីម៉ៅសេទុងត្រង់ម្ដុំក្បែរផ្សារដើមគបច្ចុប្បន្ន ។ បងជ្រូក ប្រហែលត្រូវបាត់បង់ជីវិតក្នុងសម័យប៉ុល ពត ព្រោះរហូតដល់សព្វថ្ងៃនេះ ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពីគាត់សោះឡើយ ។

ឪពុកខ្ញុំជាប់រវល់បំពេញការងារប្រចាំការិយាល័យរបស់គាត់នៅឯផ្ទះផង និង នៅទីរួមខេត្តព្រៃវែង ដើម្បីចូលរួមកាត់ក្ដីនៅសាលាដំបូងផង ។ ដូច្នេះ ក្នុងមួយខែៗ ឪពុកខ្ញុំមិនសូវនៅផ្ទះទេ ។ កាលសម័យនោះ ខេត្តព្រៃវែងចែកជា ១០ ស្រុក ក្នុង ១០ ស្រុកនោះ មានអាជ្ញាសាលាតែ ៣ នាក់ប៉ុណ្ណោះ ។ ឪពុកខ្ញុំត្រូវទទួលចាត់ការ ៣ ស្រុកគឺ៖ ស្រុកពារាំង ស្រុកស៊ីធរកណ្ដាល និង ស្រុកកញ្ជ្រៀច ។ មុខងារអាជ្ញាសាលា មិនមានបៀវត្សប្រចាំខែទេ តែទទួលកម្រៃក្នុងការសម្រេចសាលក្រម ឬប្រគល់ដីកាកោះ ។ ក្នុងសម័យនោះ អ្នកស្រុកផ្ដើមធ្វើដំណើរតាមទោចក្រយានយន្តជាបណ្ដើរៗហើយ ។ ឪពុកខ្ញុំពុំមានលទ្ធភាពទិញម៉ូតូថ្មីមកប្រើទេ ។ គាត់អាចទិញត្រឹមតែម៉ូតូចាស់មធ្យម ឬ ជំនំៗ ។ ដោយទំហំទឹកដីទាំង ៣ ស្រុកធំទូលាយ ការធ្វើដំណើរតាមម៉ូតូរបស់ឪពុកខ្ញុំ ក៏មានការលំបាក ព្រោះម៉ូតូចាស់នោះខូចញឹកញាប់ពេក ។ ពេលខ្លះឪពុកខ្ញុំត្រូវបណ្ដើរម៉ូតូរាប់គីឡូម៉ែត្រ ទម្រាំរកជាងជួសជុលមុននឹងអាចបន្តដំណើរទៅមុខទៀតបាន ។ ខ្ញុំអាណិតឪពុកខ្ញុំណាស់ ព្រោះ

គាត់មិនដែលបានប្រើម៉ូតូថ្មីសោះ ក្នុងមួយជីវិតរបស់គាត់ ។ ម៉ូតូដែលគាត់ពេញចិត្តជាងគេគឺ ម៉ូតូបារាំងម៉ាក "ម៉ូប៊ីឡែត" (Mobilette) ។ ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៦០ មក ម៉ូតូជប៉ុនម៉ាកហុងដា ស៊ុយហ្សូយគី ចាប់ផ្តើមលុកចូលមកដល់ភូមិយើងជាបន្តបន្ទាប់ តែឪពុកខ្ញុំនៅតែប្រើម៉ូតូម៉ូប៊ីឡែតដដែល ។

ដើម្បីជួយធ្វើការរបស់គាត់ ឪពុកខ្ញុំជួលជំនួយការម្នាក់ ដោយឲ្យប្រាក់ប្រចាំថ្ងៃ ។ ជំនួយការនោះ ចេះត្រឹមតែសរសេរ ឬ អានអក្សរខ្មែរតែប៉ុណ្ណោះ និង គ្មានមុខការអ្វីទៀតក្រៅពីប្រគល់ដីកាកោះ ឬ សេចក្តីជូនដំណឹងដល់កូនក្តី ទាំងដើមចោទទាំងចុងចម្លើយ ។ នៅពេលចេញទៅសម្រេចសាលក្រមរបស់តុលាការ ឪពុកខ្ញុំតែងសុំអន្តរាគមន៍ជានិច្ចពីអាជ្ញាធរមូលដ្ឋាន ជាពិសេស ពីសមត្ថកិច្ចតម្រួត ព្រោះការងារសម្រេចសាលក្រមនោះគឺ ត្រូវរឹបអូសទ្រព្យសម្បត្តិ ផ្ទះសម្បែង ឬ គោក្របីរបស់អ្នកចាញ់ យកទៅឲ្យអ្នកឈ្នះ ឬ យកទៅលក់ឡាយឡុងយកប្រាក់ទៅឲ្យអ្នកឈ្នះតាមសេចក្តីសំរេចរបស់តុលាការ ។ ការងារបែបនេះអាចមានគ្រោះថ្នាក់ណាស់ ព្រោះអ្នកចាញ់អាចមិនព្រមឲ្យរឹបអូស ហើយក៏អាចតដៃតាមអំពើហឹង្សាក៏មាន ។ ដោយសារទំនាក់ទំនងជាប់ជានិច្ចជាមួយអាជ្ញាធរមូលដ្ឋាន ជាពិសេស ជាមួយចៅហ្វាយស្រុក ឪពុកខ្ញុំក៏ក្លាយជាមន្ត្រីមានមុខមានមាត់ប្រចាំស្រុកផងដែរ ។

នៅឯផ្ទះ ក្នុងការិយាល័យរបស់គាត់ ឪពុកខ្ញុំធ្វើការផ្តល់យោបល់ខាងផ្លូវច្បាប់ដូចមេធាវីដែរ ។ ជួនកាលគាត់ជួយធ្វើពាក្យបណ្តឹងដល់គូក្តីដែលមានជម្លោះត្រូវឡើងតុលាការ ។ពាក្យមួយច្បាប់តម្លៃ ១០០ រៀល ឬ ប្រហែល ៣ ដុល្លារស.រ.អា ។ ឪពុកខ្ញុំតែងទទួលភ្ញៀវនៅក្នុងបន្ទប់ធំក្នុងផ្ទះ ។ នៅខាងក្រោយតុធំដែលយើងនាំគ្នាហៅថាសាឡុង មានកញ្ចក់ឆ្លុះមុខយ៉ាងធំ ដែលមានក្របធ្វើពីឈើឆ្លាក់ក្បាច់យ៉ាងល្អប្រណិត អមដោយរូបក្បាលទន្សោងពីរដែលមានស្នែងវែង ព្យួរជាប់ខាងលើខ្ពស់ផុតក្បាលមនុស្សចាស់ ។ ខេត្តព្រៃវែងសម័យនោះ ជាខេត្តដែលល្បីថា

មានក្តីក្តាំច្រើន ។ អតិថិជនរបស់ឪពុកខ្ញុំ ភាគច្រើនជាអ្នកស្រែចម្ការ ។ ពួកគាត់ជិះកង់កាត់ពីតំបន់នានានៃស្រុកទាំង ៣ មករកឪពុកខ្ញុំ ដើម្បីឲ្យជួយសម្រេចសាលក្រមតុលាការដែលសម្រេចឲ្យឈ្នះ ឬ មកពិភាក្សាច្បាប់ដើម្បីធ្វើពាក្យប្តឹង ឬ រកវិធីការពារខ្លួន ចំពោះពាក្យបណ្តឹងរបស់អ្នកដទៃជាដើម ។

ភាគច្រើន នៅពេលធ្វើដំណើរតាមរទេះកង់ អ្នកស្រុកទាំងនោះ ស្លៀកតែក្រមាប៉ុណ្ណោះទេ ឯខោដែលជាទូទៅជាខោឡាញ់ ពួកគាត់ចងនៅនឹងដៃកង់បង្ការកុំឲ្យទទឹក ឬ ប្រឡាក់ នៅពេលឆ្លងកាត់ទឹក ភក់ ដីហុយតាមផ្លូវជាដើម ។ ពេលមកដល់មុខផ្ទះខ្ញុំ ពួកគាត់ផ្អែកកង់ទល់នឹងទ្វាររបង រួចរលាស់ខោឡាញ់ ផ្លាស់ក្រមា ស្លៀកខោឡាញ់នោះ និង សម្អាតរាងកាយឲ្យបានសមរម្យមុននឹងចូលមកជួបឪពុកខ្ញុំ ។ នេះជាសុជីវធម៌ ឬ ការគោរពដែលអ្នកស្រែតូចតាចសម្តែងឡើង ចំពោះមន្ត្រីរាជការដែលពួកគាត់ចាត់ទុកជាអ្នកធំ ។ ចំពោះអ្នកធំ អ្នកស្រុកប្រើពាក្យ ព្រះតេជគុណ និង ពាក្យខ្ញុំបាទ ឬ បាទទានជាដើម ។ល។

នៅពេលទំនេរពីការងារ នៅផ្ទះ ឪពុកខ្ញុំដាំដំណាំដូចជា ដូង ស្វាយ ខ្នុរ ជាដើម ។ ពួកយើងមិនមានទឹកម៉ាស៊ីនស្អាតសម្រាប់ទទួលទាន និង ប្រើប្រាស់ស្រោចដំណាំទេ ។ យើងប្រើទឹកស្រះដែលស្ថិតប្រមាណ ៣០ ម៉ែត្រពីផ្ទះ។ ក្រៅពីស្រះ យើងប្រើពាងធំៗរក្សាទុកទឹកភ្លៀងសម្រាប់ទទួលទាន ។ នៅពេលអស់ទឹកភ្លៀង ឪពុកម្តាយខ្ញុំជួលកម្មករឲ្យរែកទឹកពីអណ្តូងផ្ទះអ្នកជិតខាងចម្ងាយប្រមាណ ១០០ ម៉ែត្រមកប្រើប្រាស់ ។ ក្រោយមកខ្ញុំដឹងថាពួកកម្មករដែលយើងហៅថាគូលីមិនចង់មកស៊ីឈ្នួលរែកទឹកឲ្យពួកយើងទេ ដោយអ្នកទាំងនោះខ្លាចគេយល់ច្រឡំថាពួកគាត់ជាអ្នកទោស ។ ព្រោះកាលសម័យជីតាខ្ញុំ គាត់ច្រើនប្រើអ្នកទោសឲ្យជំរះស្មៅ ឬ រែកទឹកដាក់ពាងជាញឹកញាប់ ។